# រឿង មហាចោរនៅទល់ដែន

## ភាគទី៣៤ (ព្រះនាងខត្តិយាណី)

អូនមកប៉ុន្មានថ្ងៃហើយ?ឰ

ចា៎ះ! មកដល់បីថ្ងៃហើយ។

លោកពូ អ្នកមីងសុខសប្បាយជាទេឬ?

ចា៎ះ! សុខសប្បាយទាំងអស់គ្នាទេ។ ហ៊ឺ! កុំនិយាយពីរឿងគេ យើងនិយាយពីរឿងយើងវិញ បងឥឡូវប្លែកពីដើមខ្លាំងណាស់។

ប្លែកត្រង់ណា? ប្លែកមុខ មាត់ ចិត្ត...

ប្អូនឯងក៏ប្លែកដែរ។

ប្លែកអ្វីខ្លះ?

ប្លែកត្រង់ល្អជាងមុន។

ចា៎ះ! ប្អូនពេញរូបពេញរាងហើយ។ បងក៏ល្អជាងមុនដែរ។ នារីអោនក្បាលទៅលើដើមទ្រូងមានន្ទ។ នាងឱបស្មាបុរសនឹងដៃនាងទាំងពីរ។ បុរសនិយាយទៅទៀតថា: ក្នុងជាតិនេះ បងមានជីវិតមួយរេចុះរឡើងខ្លាំងណាស់ ជីវិតបងជាជីវិតពុះពារមានការប្លែកៗរាល់ពេលរាល់វេលា។ ជនអ្នកស្រលាញ់តែសុខ មិនចូលចិត្តនឹងរស់នៅយ៉ាងនេះទេ ពីព្រោះមានភ័យមានព្រួយ មានព្រាត់ប្រាស មានជាប់គុក មានស្លាប់ មានសប្បាយ ផ្ទុយគ្នាខ្លាំងណាស់។ មានតែជនអ្នកដែលមិនគីតដល់ប្រយោជន៍ខ្លួន និងសេចក្តីសុខផ្ទាល់ខ្លួនទេដែលចូលចិត្តនឹងជីវិតរបស់បង។

ចា៎ះ! ប្អូនមិនចង់ឲ្យបងដើរផ្លូវក្រោយនេះសោះ។ ប្អូនចង់ឲ្យបងរស់នៅធ្វើការដូចគេឯងធម្មតា កុំឲ្យបងគិតការនគរធ្វើអី ព្រោះការនេះធំណាស់។

ការនគរជាការរបស់អ្នកទាំងអស់គ្នា ម្តេចក៏មិនត្រូវគិតទៅវិញ?

អត្ថបទដោយ៖ មាស សុភាព

បង! បង! ប្អូនមកនេះ មកសុំអង្វរបងឲ្យចោលគំនិតដើរផ្សងព្រេងសំណាងនោះទៅ។ សូមបងធ្វើតាមប្អូន ទុំះយើងនឹងបានជួបគ្នាជាប្ដីប្រពន្ធមិនខាន។

ទោះបងធ្វើតាមប្អូន ក៏បងត្រូវស្ដាប់បន្តិចទៀតនេះដែរ។

ទេ! ទេ! បើបងធ្វើតាមប្អូនៗអាចជួយបង។

ជួយយ៉ាងណា?

ជួយសុំលោកមា ជួយឲ្យឪពុកខ្ញុំជួយនិយាយដោះលែងបងជាមួយលោកមា។ បង! បង! តាមខ្ញុំទេ? ម្ដេចបងនៅស្ងៀម? ឱ! បង! សម្រេចថាអ៊ីមកចុះ ប្អូននឹងចាត់ចែងការនេះភ្លាមមួយរំពេច។ មានន្ទញញឹមយ៉ាងជ្រាលជ្រៅ នាងកែវមណីតឹងទ្រូងជាពន់ពេក ពីព្រោះមិនដឹងជាបុរសឆ្លើយបែបណា? នាងមើលមុខបុរស មើលភ្នែកបុរស នាងលូកដៃទៅចាប់បបូរមាត់មាណពក្រេងមាត់នេះនិយាយខុសបំណងនាង។ មាត់នេះបញ្ចេញសំដីថា:

ចុះបើមិនតាមប្អូនមិនជួយបងទេ?

ធីតាយកម្រាមដៃក្រឡួចបបូរមាត់បុរសទាំងពីរនោះ កុំឲ្យនិយាយទៀតនាងផ្ដួលខ្លួនទៅលើភ្លៅមានន្ទ រួចនិយាយយ៉ាងស្រងូតស្រងាត់ថា:

ហ៊ឺ!...ប្អូនពិបាកចិត្តណាស់...ហ៊ឺ។ ឱ! ទេវតាលោកអើយ!...ប្អូនជួយមិនបានទេ ពីព្រោះ... គ្មានពាក្យអ្វីទៅនិយាយជាមួយឪពុករបស់បង និងឪពុករបស់ខ្ញុំ។

មានន្ទយកដៃច្បូតសក់របស់នាងលេងបណ្ដើរ សួរបណ្ដើរថា:

ម៉េចក៏ដូច្នោះ?

ពីព្រោះបើបងឯងតាម ខ្ញុំអាចទៅជម្រាបលោកថា បងលះបង់គំនិតតស៊ូនោះហើយមានប្អូនជាអ្នកធានាអះអាងយកជីវិតថ្វាយ។ មានន្ទសើចដោយមើលងាយគំនិតនេះ។

អូនស្គាល់ចិត្តបងស្រាប់ហើយ។ ការដែលបងគិត បងមិនមែនគិតទាំងប្រថុយៗទេ គឺបានគិតម៉ត់ចត់ណាស់។ ម្យ៉ាងបងពុំសុខចិត្តឲ្យអូនយកនាមបងទៅជាសញ្ញាចុះចាញ់ទេ។ ទីពីរ

*បើបងស្រលាញ់អូន បងពុំសុខចិត្តឲ្យអូនយកសេចក្តីស្នេហារបស់យើងនេះ ជាគ្រឿងសម្រាប់បង្ខំបងឲ្យតាមអូននោះទេ។*

*នារីស្ទុះក្រោកពីលើភ្លៅមាននួបើកភ្នែកធំៗ មើលមុខមាននួជាថ្មី។ នាងប្រែទឹកមុខពីក្រហមឆ្អិនឆ្អៅទៅស្វាំងទៅវិញ។*

*បង! ប្រសាសន៍អ្វីដូច្នោះ ប្អូនស្រលាញ់បងទើបជាប្អូនអង្វរបងដូច្នោះ មិនមែនប្អូនធ្វើនេះដើម្បីឲ្យបងអង្វរប្អូននោះទេ។ ចាំ៎ះ! ប្អូនហ៊ាននិយាយស្រលាញ់នេះ ដោយឥតអៀនខ្មាស់ជាមួយបង។ បងស្តាប់ប្អូនឲ្យបាន កុំប្រទ្បឹឲ្យសោះ ប្អូនបញ្ជាក់ទៀតថាៈ ប្អូនអង្វរបង។ បើបងធ្វើតាមយើងនឹងបានសេចក្តីសុខមិនខាន។*

*ធ្វើយ៉ាងណា?*

*ចាំ៎ះ! បង! មនុស្សលោកកើតមកលើលោកនេះ តើប្រាថ្នាអ្វី?*

*មិនគឺប្រាថ្នាសុខគ្រប់ៗគ្នា? អ្នកខ្លះគិតថា ដើម្បីឲ្យបានសុខ ត្រូវលះបង់បុណ្យសក្តិ ប្រពន្ធកូន ទ្រព្យសម្បត្តិ ក្តីសប្បាយ អំពើអកុសល រួចព្យាយាមមកសាងបណ្តុះបណ្តាលខ្លួន តាំងខ្លួនជាមេដឹកនាំមនុស្សឲ្យចេះដឹង ឲ្យភ្ញាក់ខ្លួន រលឹកដឹងខ្លួនថា ខ្លួនជាមនុស្សនោះមានកិច្ចការយ៉ាងណាៗខ្លះ គឺព្យាយាមធ្វើគ្រួសារមនុស្សទាំងអស់ឲ្យបានសុខឡើង។ អ្នកខ្លះនឹកថា ផ្លូវខាងលើនេះខុសទេ ដើម្បីឲ្យមនុស្សបានសុខតោងអាត្មាឯងម្នាក់ៗត្រិះរកទ្រព្យធនធានសុចរិត រកបុណ្យសក្តិដោយត្រឹមត្រូវតាមកម្លាំងខ្លួន កុំយាយីធ្វើបាបឈ្នានីសគេ ទុំ៎ះគ្រួសារមនុស្សទាំងអស់នោះនឹងបានសុខមិនខាន។ ចំណែកខាងប្អូនមិនហ៊ានអារកាត់ថាគំនិតរបស់អ្នកណាខុសទេ ពីព្រោះប្អូនជាស្រី ប្រាជ្ញាខ្លី គំនិតមិនជ្រៅ មើលមិនឃើញឆ្ងាយ។ តែប្អូនយល់ឃើញថា ផ្លូវទីមួយជាផ្លូវពិបាកដើរណាស់ គឺបន្ទាមានគ្រប់ជំហាន។ ប្អូនចូលចិត្តផ្លូវទីពីរ ពីព្រោះដូចរូបបង បងមានតំរិះវិជ្ជាបរិបូណ៌ មានផ្លូវគ្រប់បែបយ៉ាងដើម្បីឲ្យបានបុណ្យសក្តិមានទ្រព្យធនធានគ្រប់គ្រាន់ដើម្បីធ្វើជាដើមទុនសម្រាប់រស់នៅនឹងខ្លួនទៅម្តេចក៏ទៅជាចង់ឈោងចាប់ផ្កាយសុខដែលនៅឆ្ងាយពីខ្លួនម្ល៉េះទៅវិញ?*

***(សូមរង់ចាំតាមដានភាគទី៣៥ នៅសប្តាហ៍ក្រោយ)***

*អត្ថបទដោយ៖ មាស សុភាព*